**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ២៩២១/៣៦ កសក.សល

ថ្ងៃ សុក្រ ១០រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៦

**ជម្រាបមក**
**លោកស្រីប្រធានក្រុមហ៊ុន ធី អ៊ី ១៦៨ អហ្វីស ស៊ីបផ្លាយ**

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់សម្ភារការិយាល័យ ប្រចាំឆ្នាំ២០២៦ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការផ្គត់ផ្គង់សម្ភារការិយាល័យ ប្រចាំឆ្នាំ២០២៦ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកស្រីប្រធាន** ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោកស្រី ដើម្បីធ្វើការផ្គត់ផ្គង់សម្ភារការិយាល័យ ប្រចាំឆ្នាំ២០២៦ ជូនអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន**៦០៦ ៩៩៧ ៩០០៛០០**(**ប្រាំមួយរយប្រាំមួយលានប្រាំបួនរយកៅសិបប្រាំពីរពាន់ប្រាំបួនរយរៀលគត់**) ជាតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **លោកស្រីប្រធាន** ជ្រាបជាព័ត៌មានតាមការគួរ។

សូម **លោកស្រីប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋលេខាធិការ**

**គីម សុន**

**ចម្លងជូន៖**
-ក្រុមហ៊ុន ជី.អ ស្ទេសិនរី(ខេមបូឌា)
-ក្រុមហ៊ុន ផប អហ្វីស ស្ទេសិនរី
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ